# សៀវភៅជាមួយនឹងសេចក្ដីសន្យា

អែលឌើរ ក្រេហ្គ ស៊ី គ្រីស្ទិនសិន
នៃពួក70 នាក់

*ខ្ញុំអធិស្ឋានថា យើងនឹងបន្តប្រើប្រាស់ព្រះគម្ពីរមរមនៈ សក្ខីបទមួយទៀតរបស់ព្រះយេស៊ូវគ្រីស្ទ ដើម្បីចែកចាយសារលិខិតដំណឹងល្អជាមួយគ្រួសារ និងមិត្តភក្តិ ។*

បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ វាគឺជាឯកសិទ្ធិដ៏ពិសិដ្ឋដើម្បីចូលរួមជាមួយនឹងអ្នកនៅក្នុងការគាំទ្រដល់ប្រធាន ថូម៉ាស អេស ម៉នសុន និងទីប្រឹក្សារបស់លោកនៅក្នុងគណៈប្រធានទីមួយ និងពួកសាវកដប់ពីរនាក់ ជាព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈ ។ ខ្ញុំធ្វើទីបន្ទាល់ថា ពួកព្យាការី "និយាយដូចដែលបានបណ្ដាលដោយព្រះវិញ្ញាណបរិសុទ្ធ ។

"ហើយអ្វីក៏ដោយដែលពួកគេនឹងនិយាយ កាលណាបណ្ដាលដោយព្រះវិញ្ញាណបរិសុទ្ធ នោះនឹងទៅជាបទគម្ពីរ នឹងទៅព្រះហឫទ័យនៃព្រះអម្ចាស់... ហើយជាព្រះចេស្ដានៃព្រះ ចំពោះសេចក្ដីសង្គ្រោះ" (សូមមើល គ និង ស 68:3--4) ។

ក្នុងនាមជាសមាជិកនៃសាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ យើងមានផលប្រយោជន៍ និងពរជ័យនៃបទគម្ពីររស់ ដូចដែលបានប្រកាសដោយអ្នកទាំងឡាយ ដែលបានគាំទ្រឱ្យធ្វើជាពួកព្យាការី ក៏ដូចជាបទគម្ពីរបរិសុទ្ធដែលមាននៅក្នុងព្រះគម្ពីរប៊ីប ព្រះគម្ពីរមរមន គោលលទ្ធិ និងសេចក្ដីសញ្ញា និងមុក្ដាដ៏មានតម្លៃមហិមា ។ ព្យាការីនីហ្វៃបានសរសេរថា "ត្បិតព្រលឹងខ្ញុំត្រេកអរចំពោះបទគម្ពីរទាំងឡាយ ឯចិត្តខ្ញុំរំពឹងគិតពីបទគម្ពីរទាំងនោះ ហើយខ្ញុំក៏សរសេរទុក ដើម្បីជាការចេះដឹង និងជាប្រយោជន៍ដល់កូនចៅខ្ញុំ" (នីហ្វៃទី 2 4:15) ។ បទគម្ពីរដែលបានសរសេរទុក ជាពិសេសព្រះគម្ពីរមរមនបាននាំយើងឱ្យជឿដល់ព្រះ "ហើយឱ្យស្រុះស្រួលនឹងទ្រង់ទៅតាមរយៈដង្វាយធួននៃព្រះគ្រីស្ទ គឺជាព្រះរាជបុត្រាបង្កើតតែមួយរបស់ទ្រង់" (យ៉ាកុប 4:11) ។

កាលពីពីរបីខែកន្លងទៅ មិត្តភក្ដិម្នាក់ និងខ្ញុំ មានឱកាសដើម្បីបង្ហាញព្រះគម្ពីរមួយឈុតទៅឱ្យអ្នកស្គាល់គ្នាម្នាក់ដែលមិនមែនជាសមាជិកនៃសាសនាចក្រ ។ ដោយដឹងថាគម្ពីរនេះអាចនឹងជាព្រឹត្តិការណ៍នៃការផ្លាស់ប្ដូរជីវិតសំរាប់គាត់មួយ--- ហើយចំពោះយើង--- យើងចំណាយពេលបោះពុម្ពឈ្មោះគាត់នៅលើគម្ពីរនីមួយៗ ។ នៅពេលយើងបង្ហាញកំណត់ត្រាពិសិដ្ឋទាំងនេះទៅឱ្យគាត់ យើងអាចប្រាប់ថាគាត់មានការរំភើបចិត្តយ៉ាងជ្រាលជ្រៅ ដោយសារការផ្ដល់ឱ្យដ៏មានតម្លៃ និងដោយភាពស្មោះស្ម័គ្ររបស់យើង ។ អស់រយៈពេលប្រហែលជាប៉ុន្មាននាទី គាត់បានពិនិត្យមើលក្នុងគម្ពីរនីមួយៗដោយគ្មាននិយាយអ្វីសោះ យកដៃរបស់គាត់អង្អែលនៅលើគំរប ហើយបើកមើលទំព័រខ្លះៗ ។

ដោយដឹងអំពីសារៈសំខាន់នៃខណៈនោះ យើងបានជួយគាត់ឱ្យបើកទៅទំព័រចំណងជើងនៃព្រះគម្ពីរមរមន ហើយចាប់ផ្ដើមពន្យល់ថាព្រះគម្ពីរមរមនគឺជាសក្ខីយបទ ឬជាសាក្សីមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ ។ រួចមកគាត់សួរសំណួរមួយដែលសមាជិកមានគំនិតជាអ្នកផ្សព្វផ្សាយសាសនាទាំងអស់ចង់ឮយ៉ាងខ្លាំងថាៈ "ហេតុអ្វីបានជាយើងចាំបាច់ត្រូវការសាក្សីបន្ថែមអំពីព្រះយេស៊ូវគ្រីស្ទ ក្រៅពីព្រះគម្ពីរប៊ីប?" ជំនួសឱ្យការឆ្លើយភ្លាមៗ យើងបានសួរគាត់ថា

ហេតុអ្វីបានជាគាត់គិតថារឿងនេះអាចថាជារឿងសំខាន់។ ចម្លើយរបស់គាត់ហាក់ដូចជាកាន់តែបំផុសគំនិតជាងសំណួររបស់គាត់។ គាត់បានឱ្យយោបល់ថា ចាប់តាំងពីមានកើតចេញនូវការផ្លាស់ប្តូរយ៉ាងច្រើននៃព្រះគម្ពីរប៊ីប និងការបង្រៀនក្នុងនោះមក យើងត្រូវការសម្លេងបញ្ជាក់មួយចំនួនផងដែរ ជាអ្វីមួយដែលនឹងជួយយើងឱ្យយល់ព្រះគម្ពីរប៊ីបកាន់តែប្រសើរ។ ការថ្លែងរបស់គាត់ បានបើកទ្វារឱ្យយើងដើម្បីចែកចាយអំពីអារម្មណ៍ និងទីបន្ទាល់របស់យើង ស្តីអំពីព្រះគម្ពីរប៊ីប និងព្រះគម្ពីរមរមន។

យើងចាប់ផ្តើមដោយការបង្ហាញអំពីការជឿស៊ប់ និងការផ្លាស់ប្រែចិត្តជឿអស់ពីចិត្តរបស់យើងចំពោះ គោលលទ្ធិ និងការបង្រៀនទាំងឡាយនៃព្រះគម្ពីរប៊ីប ជាពិសេសគម្ពីរសញ្ញាថ្មី។ កាលដែលយើងអាចអានបន្ទូលរបស់ព្រះអង្គសង្គ្រោះជាច្រើន នៅពេលដែលទ្រង់បានបង្រៀនដំណឹងល្អ អំឡុងពេលការបំរើរបស់ទ្រង់នៅលើផែនដី ពង្រឹងដល់យើង ជួយយើងឱ្យមកស្គាល់ទ្រង់ ហើយបង្រៀនយើងថា យើងអាចប្រែក្លាយឱ្យកាន់តែដូចទ្រង់។ រួចហើយយើងអះអាងថា ដូចជាព្រះគម្ពីរប៊ីបដែរ ព្រះគម្ពីរមរមនគឺជាភស្តុតាងបន្ថែមថា ព្រះស្រឡាញ់កូនចៅរបស់ទ្រង់ទាំងអស់ ហើយបានប្រទានផ្លូវមួយសំរាប់យើងដើម្បីត្រឡប់ទៅ និងរស់នៅជាមួយទ្រង់ម្តងទៀត។ យើងបានចំណាយពេលក្រោយមកទៀត ដើម្បីពិនិត្យមើលនូវទិដ្ឋភាពជាច្រើនអំពីព្រះគម្ពីរមរមន រួមទាំងប្រវត្តិ និងដើមហេតុនៃទេវភាពរបស់គម្ពីរ។ ខ្ញុំសូមអនុញ្ញាតដើម្បីចែកចាយនូវរឿងមួយចំនួនដែលយើងបានពិភាក្សា។

### សៀវភៅជាមួយនឹងសេចក្តីសន្យា

ជាដំបូងយើងបានពន្យល់ថា ព្រះគម្ពីរមរមនគឺជាសៀវភៅជាមួយនឹងសេចក្តីសន្យា។ ថ្វីត្បិតប្រវត្តិរបស់វាសំខាន់ណាស់ វាគឺជាសៀវភៅបទគម្ពីរមួយយ៉ាងសំខាន់ដែលគួរតែត្រូវបានទទួល និងអាននៅក្រោមឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ។ អស់អ្នកទាំងឡាយណាដែលសិក្សា និងពិចារណាអំពីការបង្រៀន របស់ព្រះគម្ពីរមរមន គឺត្រូវបានផ្តល់នូវការសន្យាមួយ ដែលមាននៅក្នុងជំពូកចុងក្រោយ នៃគម្ពីរម៉ូរ៉ូណៃ (សូមមើលម៉ូរ៉ូណៃ 10:3--4) ក៏ដូចជានៅក្នុងបុព្វកថានាំទៅកាន់ព្រះគម្ពីរមរមនដែរ ដែលយើងអានថា: "យើងសូមអញ្ជើញមនុស្សទាំងអស់នៅគ្រប់ទិសទី សូមឱ្យអានព្រះគម្ពីរមរមន សូមឱ្យពិចារណាមើលនៅក្នុងចិត្តនូវពាក្យពេចន៍នៅក្នុងគម្ពីរនេះ ហើយបន្ទាប់មកសូមឱ្យសួរដល់ព្រះជាព្រះវរបិតាដ៏នៅអស់កល្បជានិច្ច ដោយនូវព្រះនាមនៃព្រះគ្រីស្ទ ថាតើគម្ពីរនេះពិតឬទេ។ អស់អ្នកណាដែលធ្វើតាមបែបបទនេះ ហើយសូមសួរដោយសេចក្តីជំនឿ នោះនឹងបានទទួលសេចក្តីបន្ទាល់អំពីសេចក្តីពិត និងទេវភាពរបស់គម្ពីរនេះ ដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ"។ បន្ទាប់មកយើងចំណាយពេលប៉ុន្មាននាទីបង្រៀនអំពីការអធិស្ឋាន និងរបៀបដែលព្រះវិញ្ញាណបរិសុទ្ធ អាចមានបន្ទូលមកកាន់ដួងចិត្តរបស់យើង ហើយបញ្ជាក់ថាព្រះគម្ពីរមរមនពិត។

### សៀវភៅជាមួយនឹងគោលបំណង

បន្ទាប់មកយើងបានថ្លែងថាព្រះគម្ពីរមរមន គឺជាសៀវភៅជាមួយនឹងគោលបំណង។ យើងអានមកពីទំព័រចំណងជើងថា ព្រះគម្ពីរមរមន "ត្រូវបានសរសេរតាមរយៈការបញ្ជា" និង "ដោយវិញ្ញាណនៃការព្យាករណ៍ និងវិវរណៈ" ដើម្បី "នាំចេញមកឱ្យឃើញដោយព្រះអំណោយទាន និងដោយព្រះចេស្តារបស់ព្រះ" ដើម្បីជាការបរិវត្តិន៍ដល់ពួកយើង

ម្នាក់ៗ "ថាព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ ជាព្រះដ៏នៅអស់កល្បជានិច្ច"។ នៅក្នុងការបង្ហាញផ្ទាល់ខ្លួនអំពីគោលបំណងនេះ នីហ្វៃ ក្នុងនាមជាអ្នកនិពន្ធមួយរូបក្នុងចំណោមអ្នកនិពន្ធទាំងឡាយនៃព្រះគម្ពីរមរមន បានសរសេរថា "ត្បិតភាពពោរពេញនៃចេតនារបស់ខ្ញុំ គឺដើម្បីឱ្យខ្ញុំអាចបញ្ចុះបញ្ចូលមនុស្ស ឱ្យមករកព្រះនៃអ័ប្រាហាំ និងព្រះនៃអ៊ីសាក និងព្រះនៃយ៉ាកុប ហើយបានសង្គ្រោះ" (នីហ្វៃទី1 6:4)។

## សៀវភៅដែលបង្រៀនអំពីផែនការនៃសុភមង្គលដ៏មហិមា

បន្ថែមពីលើនោះ យើងបានពន្យល់ថាព្រះគម្ពីរមរមន គឺជាសៀវភៅមួយដែលបង្រៀនអំពី "ផែនការនៃសុភមង្គលដ៏មហិមា" (អាលម៉ា 42:8; សូមមើលផងដែរខ 5, 13, 31; នីហ្វៃទី 2 9)។ ប៉ុន្តែនៅក្នុងពាក្យដ៏បំផុសគំនិត និងដែលអាចយល់បាន ព្រះគម្ពីរមរមនបង្រៀនអំពីគោលបំណងនៃជីវិត ថាយើងមកពីកន្លែងណា ហើយអ្វីកើតឡើងនៅពេលយើងស្លាប់។ យើងរៀនអំពីសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ និងពលិកម្មដង្វាយធួនរបស់ទ្រង់ អំពីការប្រែចិត្ត អំពីសារៈសំខាន់នៃពិធីបុណ្យជ្រមុជទឹកដោយការជ្រមុជ និងអំពីអំណោយទាន និងព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ។ តាមរយៈការសិក្សា និងការទទួលទានគោលលទ្ធិទាំងឡាយនៃព្រះគម្ពីរមរមន យើងទទួលបាន "ការភ្លឺថ្លានៃសេចក្តីសង្ឃឹមដ៏ឥតខ្ចោះ ហើយដោយមានចិត្តស្រឡាញ់ព្រះ និងមនុស្សគ្រប់រូប" ជាមួយនឹងបំណងប្រាថ្នាដើម្បី "ស៊ូទ្រាំដល់ទីបំផុត" ដើម្បីយើងអាចបាន "ជីវិតដ៏នៅអស់កល្បជានិច្ច" (នីហ្វៃទី 2 31:20)។

## សៀវភៅដែលថ្លែងបន្ទាល់ថាព្រះយេស៊ូវគឺជាព្រះគ្រីស្ទ

ដែលសំខាន់បំផុតនោះ យើងបានប្រកាសថា ព្រះគម្ពីរមរមនគឺជាសៀវភៅមួយ ដែលថ្លែងទីបន្ទាល់ថាព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃពិភពលោក។ ពួកព្យាការីដ៏មហិមានៅក្នុងព្រះគម្ពីរមរមន បានថ្លែងនូវសាក្សីដ៏ឧឡារិកថា ព្រះយេស៊ូវគ្រីស្ទ គឺជាអង្គបង្កបង្កើតនៃផែនដី (សូមមើលម៉ូសាយ 3:8) ព្រះប្រោសលោះរបស់មនុស្សជាតិ (សូមមើលហេលេមិន 5:9--12) ជាបុត្រាសំណប់តែមួយរបស់ព្រះវរបិតា (សូមមើលនីហ្វៃទី1 11:18--21; យ៉ាកុប 4:11)។ ពួកព្យាការីនៃព្រះគម្ពីរមរមនទាំងនេះបានស្គាល់ទ្រង់ ដូចជាលោកអ័ប្រាហាំ និងលោកម៉ូសេដែរ ហើយបានទទួល និងបង្រៀនអំពីដំណឹងល្អដ៏គ្មានទីបញ្ចប់របស់ទ្រង់។ នៅពេលយើងអាន និងសិក្សាពាក្យសំដីរបស់ពួកលោក យើងទទួលបាននូវការយល់ដឹងកាន់តែខ្លាំងឡើង អំពីសេចក្តីស្រឡាញ់ដែលមិនអាចប្រៀបផ្ទឹមបានរបស់ព្រះអង្គសង្គ្រោះ ជីវិតដ៏ល្អឥតខ្ចោះ និងគំរូរបស់ទ្រង់ និងពរជ័យទាំងឡាយនៃពលិកម្មដង្វាយធួនដ៏មហិមារបស់ទ្រង់។

## សៀវភៅដែលបញ្ជាក់ការពិតអំពីបេសកកម្មជាព្យាការីរបស់លោកយ៉ូសែប ស៊្មីធ

រួចហើយយើងបានថ្លែងបន្ទាល់ថា ព្រះគម្ពីរមរមនគឺជាភស្តុតាងជាក់ស្តែងថា លោកយ៉ូសែប ស៊្មីធ ត្រូវបានជ្រើសរើសដោយព្រះហស្តរបស់ព្រះអម្ចាស់ ដើម្បីស្តារសាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទ នៅលើផែនដីឡើងវិញនៅក្នុងថ្ងៃចុងក្រោយ។ ដូចដែលបានថ្លែងនៅក្នុងបុព្វកថាព្រះគម្ពីរមរមនថា "អស់អ្នកណាដែលបានទទួលទីបន្ទាល់ដ៏ប្រសើរពីព្រះវិញ្ញាណបរិសុទ្ធក៏នឹងបានដឹងដោយសារព្រះចេស្តាដដែលថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះអង្គសង្គ្រោះនៃពិភពលោក ថាយ៉ូសែប ស៊្មីធ គឺជាអ្នកទទួលវិវរណៈ និងជាព្យាការីរបស់ទ្រង់ នៅជាន់ចុងក្រោយបង្អស់ ហើយថា សាសនាចក្រនៃ

ព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយគឺជានគរនៃព្រះអម្ចាស់ដែលបានសាងឡើងវិញម្ដងទៀតនៅលើផែនដី ដើម្បីរៀបចំសំរាប់ការយាងមកជាលើកទីពីរនៃព្រះមែស៊ី។

ចាប់តាំងពីពេលសាំយ៉ូអែល ស្ម៊ីធ បានបញ្ជូនចេញទៅផ្សព្វផ្សាយដំណឹងល្អដោយមានព្រះគម្ពីរមរមន តែពីរបីក្បាលដែលជាការបោះពុម្ពលើកដំបូង ព្រះគម្ពីរមរមនបានប្រទានពរដល់ជីវិតមនុស្សរាប់លាននាក់ នៅជុំវិញពិភពលោក។ ខ្ញុំអធិស្ឋានថាយើងនឹងបន្តប្រើប្រាស់ព្រះគម្ពីរមរមនៈ ជាសក្ខីយបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ ដើម្បីចែកចាយសារដំណឹងល្អជាមួយនឹងគ្រួសារ និងមិត្តភក្តិ។ បើយើងធ្វើដូចនេះ ដូចជាករណីដែលយើងធ្វើជាមួយនឹងមិត្តជាទីស្រឡាញ់របស់យើង មនុស្សជាច្រើននឹងឆ្លើយតបជាមួយនឹងចំណាប់អារម្មណ៍ដ៏ខ្លាំង ដើម្បីដឹងបន្ថែមអំពីជីវិត និងបេសកកម្មរបស់ព្រះអង្គសង្គ្រោះ និងផែនការនៃសុភមង្គលដ៏មហិមារបស់ទ្រង់សំរាប់យើងម្នាក់ៗ។

ខ្ញុំសូមបង្ហាញជាសាក្សីយ៉ាងឧឡារិកថា ព្រះគម្ពីរមរមនពិត។ វាគឺជាសៀវភៅមួយ ដែលបាននាំឱ្យមានការផ្លាស់ប្ដូរយ៉ាងធំមួយនៅក្នុងជីវិតរបស់ខ្ញុំ។ ខ្ញុំដឹងថាព្រះមានព្រះជន្ម។ ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ។ ដំណឹងល្អរបស់ទ្រង់ត្រូវបានស្ដារឡើងវិញនៅលើផែនដី។ ប្រធានថូម៉ាស អេស ម៉នសុន គឺជាព្យាការីរបស់ព្រះ និងជាអ្នកអធិប្បាយរបស់ទ្រង់ដែលនៅរស់នៅជំនាន់នេះ។ ព្រះវិញ្ញាណដែលខ្ញុំមាន នៅពេលខ្ញុំអាន ពិចារណា និងអធិស្ឋានជាប្រចាំអំពីព្រះគម្ពីរមរមន បានជួយពង្រឹងដល់ការយល់ដឹង និងទីបន្ទាល់របស់ខ្ញុំអំពីរឿងទាំងនេះ ហើយបញ្ជាក់ជាថ្មីចំពោះខ្ញុំថា វាជាការពិត។ ខ្ញុំសូមចែកចាយទីបន្ទាល់នេះដោយរាបសារ និងជាសាក្សីផ្ទាល់ខ្លួនរបស់ខ្ញុំជាមួយអ្នក នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។